ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 12 / 2014
ម៉ោង (Time/Heure): 14:55
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ប្រធានអង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២/០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **ការកំណត់កាលបរិច្ឆេទសម្រាប់ការជំទាស់ទៅនឹងឯកសារផ្សេងៗទាក់ទងនឹងសំណុំរឿង ០០២/០២**

១. ជាការឆ្លើយតបទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះ ឯកសារ E305 សហព្រះរាជអាជ្ញា (ឯកសារ E305/13 និងឯកសារ E305/13/1) មេធាវីការពារក្តី ខៀវ សំផន (ឯកសារ E305/12) មេធាវីការពារក្តី នួន ជា (ឯកសារ E307/5) និងសហមេធាវីនាំមុខតំណាងដើម បណ្តឹងរដ្ឋប្បវេណី (ឯកសារ E305/14 និងឯកសារ E307/6) បានដាក់បញ្ជីឯកសារដែលពួកគេបានស្នើសុំ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២។

២. អង្គជំនុំជម្រះសាលាដំបូង រម្លឹកអំពីយុត្តិសាស្ត្ររបស់ខ្លួនក្នុងការទទួលយកឯកសារផ្សេងៗនៅក្នុងក្របខណ្ឌការងារ អ.វ.ត.ក (មើល ឧទាហរណ៍ ឯកសារ E185, E185/1, E185/2) រួមទាំងការទទួលយកកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹករបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ E96/7 និងឯកសារ E299) ផងដែរ។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានសម្រេចកាលពីពេលកន្លងមកថា ក្រោមលក្ខខណ្ឌមួយចំនួន កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ត្រូវបានទទួលយក ដោយគ្មានការសួរដេញដោលតទល់នឹងអ្នកផ្ត

ល់ចម្លើយនៅក្នុងតុលាការនោះទេ។ កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹក ដែលបង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បើគ្មានករណីលើកលែងទេ គឺមិនអាចទទួលយកបាននោះទេ ប្រសិនបើភាគីមិនមានឱកាសក្នុងការសួរដេញដោលតទល់អ្នកផ្តល់ចម្លើយនោះ នៅក្នុងសវនាការ (មើលឯកសារ E96/7 កថាខណ្ឌ ២១ ដល់ ២២ ឯកសារ E299 កថាខណ្ឌ ១៧ ដល់ ១៨)។

៣. ភាគីណាមួយដែលបានស្នើសុំដាក់កំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹកនៅក្នុងបញ្ជីឯកសារសម្រាប់សំណុំរឿង ០០២/០២ ត្រូវតែបញ្ជាក់ថា តើខ្លួនមានបំណងប្រើប្រាស់ឯកសារទាំងនោះជាភ័ស្តុតាងសម្រាប់បង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែរឬទេ ហើយត្រូវដាក់សេចក្តីបញ្ជាក់នោះមកអង្គជំនុំជម្រះសាលាដំបូងមិនឱ្យលើសពីថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ឡើយ។ ភាគីត្រូវបានរំឭកថា ភាគីអាចស្នើឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ឬប្រតិចារឹក ដែលអាច *ក្នុងចំណោមនោះ* មានភ័ស្តុតាងទាក់ទងនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ក្នុងគោលបំណងក្រៅពីការបង្ហាញពីអំពើ និងអាកប្បកិរិយាផ្ទាល់របស់ជនជាប់ចោទ។ ក្នុងករណីដែលមានការទទួលយកឯកសារទាំងនេះ ហើយភាគីមិនមានឱកាសក្នុងការសួរដេញដោលតទល់នឹងអ្នកផ្តល់ចម្លើយនោះទេ អង្គជំនុំជម្រះនឹងមិនពឹងផ្អែកទៅលើផ្នែកនៃភ័ស្តុតាងទាំងនោះ ធ្វើជាមូលដ្ឋានដើម្បីបង្ហាញពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទឡើយ (មើលផងដែរ ឯកសារ E299 កថាខណ្ឌ ២៣ កថាខណ្ឌ ២៨)។

៤. ដើម្បីសម្រេចលើការទទួលយកឯកសារផ្សេងៗដែលភាគីបានស្នើឡើងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសឱ្យភាគីដាក់សេចក្តីជំទាស់ជាលាយលក្ខណ៍អក្សរចំពោះឯកសារផ្សេងៗដែលមាននៅក្នុងបញ្ជីឯកសាររបស់ភាគី។

៥. អង្គជំនុំជម្រះសាលាដំបូងក៏រំឭកដល់សេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនកាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ ដោយនៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានផ្តល់ការសន្មតអំពីភាពពាក់ព័ន្ធ និងភាពទុកចិត្តបានចំពោះឯកសារដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ។ អង្គជំនុំជម្រះសាលាដំបូងក៏ផ្តល់ឱកាសដល់ភាគីក្នុងការជំទាស់ទៅនឹងការសន្មតនេះ ដោយត្រូវដាក់ការជំទាស់ដែលមានសំអាងហេតុ ពាក់ព័ន្ធនឹងឯកសារផ្សេងៗដែលត្រូវបានយោងនៅក្នុងជើងទំព័រនៃកថាខណ្ឌក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ (មើល ឯកសារ E301/9/1.1)។

៦. សេចក្តីជំទាស់ទៅនឹងឯកសារនៅក្នុងបញ្ជីឯកសារដែលភាគីបានស្នើឡើង ឬនៅក្នុងដីកាដំណោះស្រាយ ត្រូវដាក់មិនឲ្យហួសពីថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៥។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចអំពីការទទួលយកឯកសារទាំងនោះ នៅក្នុងរយៈពេលមួយសមស្រប។

៧. អង្គជំនុំជម្រះបញ្ជាក់ថា ភាគីត្រូវទទួលខុសត្រូវក្នុងការធានាយ៉ាងណាឲ្យឯកសារដែលនឹងត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០២/០២ (មើលផងដែរ ឯកសារ E315 កថាខណ្ឌ ១៣) ដាក់ទាន់ពេលវេលា ហើយមានគ្រប់ភាសាផ្លូវការទាំងអស់របស់ អ.វ.ត.ក និងបង្គាប់ឲ្យភាគីសហការជាមួយអង្គភាពបកប្រែភាសា ប្រសិនបើចាំបាច់។